# លិខិតចំហ

## ស្តីពីការរើសអើងនិងការគម្រាមកំហែងដល់អាយុជីវិត ក្រុមគ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍នៅសហគមន៍បុរីកីឡា

---

ថ្ងៃទី 24 ខែកក្កដា ឆ្នាំ២០០៩

## សម្តេច ហ៊ុន សែន

នាយករដ្ឋមន្ត្រី

ការិយាល័យនាយករដ្ឋមន្ត្រី

លេខ ៣៨ មហាវិថីសហព័ន្ធរ៉ូស្ស៊ី

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## ឯកឧត្តម ម៉ម ប៊ុនហេង

ក្រសួងសុខាភិបាល

អាគារលេខ ១៥១-១៥៣ មហាវិថីកម្ពុជាក្រោម

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## ឯកឧត្តមជាទីគោរព

រាជរដ្ឋាភិបាលកម្ពុជាមានជោគជ័យដោយបានការទទួលស្គាល់ជាអន្តរជាតិចំពោះកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីផ្តល់ការបង្ការ ការព្យាបាល ការថែទាំ និងការគាំទ្រដល់អ្នករស់នៅជាមួយមេរោគអេដស៍។ ក៏ប៉ុន្តែ យើងខ្ញុំជាបុគ្គលនិងជាអង្គការដែលចុះហត្ថលេខាខាងក្រោម សរសេរជូនឯកឧត្តមនៅពេលនេះ គឺបំណងសម្តែងកង្វល់ដ៏មហាជ្រាលជ្រៅចំពោះការរើសអើង និងគម្រាមកំហែងដល់អាយុជីវិតជាសក្តានុពល ទៅលើក្រុមគ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍មកពីសហគមន៍បុរីកីឡា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ២០០៩ គ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ចំនួន ២០ គ្រួសារ បានត្រូវបានគេបណ្តេញចេញពីបុរីកីឡា និងបញ្ជូនទៅកាន់ទួលសំបូរ ដែលជាតំបន់តាំងលំនៅថ្មីដាច់ស្រយាល មួយ ដែលបង្កើតឡើងដោយរដ្ឋាភិបាលនៅជាយក្រុង ។ ការបណ្តេញចេញនេះបានធ្វើឡើង ទោះជាមានការ អំពាវនាវម្តងហើយម្តងទៀតទៅរដ្ឋាភិបាល រួមមានទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិនិងអន្តរ ជាតិចំនួន ១៨ និងបណ្តាញជាតិរបស់អ្នករងផលប៉ះពាល់ដោយមេរោគអេដស៍ក៏ដោយ ។

យើងខ្ញុំមានហេតុផលដ៏គួរឱ្យព្រួយបារម្ភណ៍ដែលថា ការតាំងទីលំនៅថ្មីរបស់គ្រួសារដែលរងផលប៉ះពាល់ដោយ មេរោគអេដស៍កំពុងតែបន្តទៅទៀត ទោះជាយើងខ្ញុំចុះហត្ថលេខាលើលិខិតនេះក៏ដោយ ។

យើងខ្ញុំមានអារម្មណ៍សៅហ្មងយ៉ាងខ្លាំង ដោយសារតែអាជ្ញាធរបានបង្កើតឡើងនូវនិគមជនជំងឺអេដស៍មួយ កន្លែងនៅឯទួលសំបូរ ។ ដោយដាក់ឱ្យតាំងនៅទីវាលដ៏កណ្តោចកណ្តែង និងរាបផ្ទាល់នឹងទឹកលិចក្នុងតំបន់ពាក់ កណ្តាលជនបទ ចម្ងាយ ២៥ គីឡូម៉ែត្រពីរាជធានីភ្នំពេញ ។ ទួលសំបូរគឺនៅឆ្ងាយពីកន្លែងធ្វើការ កន្លែង ព្យាបាល និងសេវាគាំទ្រ ដែលងាយរកបានកាលពេលនៅឯលំនៅឯបុរីកីឡាក្នុងរាជធានី ។

ស្ថានភាពលំនៅដ្ឋាននៅឯទួលសំបូរមិនមានលក្ខណៈគ្រប់គ្រាន់ទាល់តែសោះ ទាំងទំហំ សុវត្ថិភាពពីភ្លើងឆេះ និងអនាម័យ ។ អ្នកតាំងទីលំនៅរស់នៅពាក់ពពូនគ្នាក្នុងជម្រកស័ង្កសីដែលមិនសូវមានខ្យល់ចេញចូល ដូចជា ឡកំដៅនំក្នុងពេលថ្ងៃ ។ គ្មានចង្ក្រាន និងគ្មានប្រព័ន្ធទឹកហូរក្នុងជម្រក ដែលដាក់ខ័ណ្ឌដោយលូរសំអុយគ្មាន គ្របបិទបាំង និងមានតែអណ្តូងទឹកសាធារណៈតែមួយគត់បម្រើដល់គ្រួសារដែលគេបណ្តេញចេញទាំងអស់ ។ យោងតាមគ្រូពេទ្យគ្មានព្រំដែន ស្ថានភាពទាំងនេះមិនតម្រូវតាមបទដ្ឋានអប្បបរមាអន្តរជាតិសម្រាប់ការផ្តល់ លំនៅដ្ឋានបណ្តោះអាសន្នក្នុងគ្រាអាសន្នឡើយ ។

អំឡុងពេលដែលមនុស្សគ្មានលំនៅដ្ឋានដទៃទៀតពីរាជធានីភ្នំពេញ ត្រូវគេគ្រោងឱ្យមកតាំងទីលំនៅថ្មីនៅផ្ទះ ថ្មនៅឯផ្នែកម្ខាងជិតគ្នានៅទួលសំបូរនោះ គ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ពីបូរីកីឡា ត្រូវ បានគេដាក់ឱ្យតាំងទីលំនៅដាច់ដោយឡែកមួយជាមួយនិងលំនៅដែលអន់ជាង ដោយរំលេចឱ្យឃើញផ្សេងគ្នា

តាមរយៈដំបូលនិងជញ្ជាំងស័ង្កសីរួញពណ៌បៃតង។ ទោះជាមុនការបណ្តេញចេញ ឱ្យមកតាំងទីនៅទីនោះក៏ ដោយ ប្រជាពលរដ្ឋមូលដ្ឋានបាននិយាយសំដៅទៅរកជម្រកបៃតងថាជា "ភូមិអ្នកកើតអេដស៍"។

ការបណ្តេញនៅបូរីកីឡា ត្រូវបានគេធ្វើឡើងដើម្បីត្រួសត្រាយផ្លូវសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចមួយ ដែលបានផ្តល់ការយល់ព្រមដោយរដ្ឋាភិបាលក្នុងឆ្នាំ២០០៣ ដោយមានការយល់ព្រមថា អ្នកអភិវឌ្ឍនឹងសាងសង់ផ្ទះថ្មីនៅជ្រុងម្ខាងទៀតសម្រាប់អ្នកតាំងលំនៅជាផ្លូវការតាមគម្រោងនោះ។ ដោយមានភាពខុសប្លែកពីធម្មតាមួយ ចំនួនគ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍តាំងពីដើមមកដល់ឥឡូវនេះ ដែលគេឱ្យផ្លាស់កន្លែងដោយសារតែការអភិវឌ្ឍ មិនត្រូវបានគេជ្រើសរើសឱ្យមានសិទ្ធិស្របច្បាប់សម្រាប់ការតាំងលំនៅដ្ឋាននៅនឹងកន្លែងទេ – គឺមិនដូចជាគ្រួសារដទៃទៀត ដែលមិនទទួលរងផលប៉ះពាល់ដោយមេរោគអេដស៍ឡើយ។ បន្ទាប់ពីការរងចាំអស់រយៈពេលពីរឆ្នាំមក ឥឡូវនេះអាជ្ញាធរបានទទួលស្គាល់ថា យ៉ាងហោចណាស់មាន ១១ គ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ ដែលបានបញ្ជូលទៅទួលសំបូរកាលពីមុន មានសិទ្ធិទទួលបានលំនៅដ្ឋានថ្មីនៅផ្នែកម្ខាងទៀតនៅឯបូរីកីឡា។ ក៏ប៉ុន្តែ មកទល់នឹងថ្ងៃនេះ ១១ គ្រួសារនេះនៅតែស្ថិតនៅឯបូរីកីឡា និងមិនត្រូវបានគេផ្តល់ឱ្យនូវផ្ទះថ្មីនៅឡើយទេ។

ចំពោះគ្រួសារដទៃទៀតដែលបានបណ្តេញចេញទៅទួលសំបូរ តាមសេចក្តីរាយការណ៍មកថា ក្រសួងសុខាភិបាលបានផ្តល់ការធានាថា ការផ្តល់ថ្នាំប្រឆាំងមេរោគអេដស៍ និងការព្យាបាលជំងឺឱកាសនិយម នឹងមានសម្រាប់ពួកគេ។ ក៏ប៉ុន្តែ វាមិនច្បាស់លាស់ឡើយដែលថា ក្រសួងមានគម្រោងរយៈពេលយូរច្បាស់លាស់ដើម្បីធានាចំពោះរឿងនេះឬអត់។ ចាប់តាំងពីមានការបណ្តេញមក រដ្ឋាភិបាលមិនបានផ្តល់សេវាដោយផ្ទាល់ឡើយ ដូចជាការផ្តល់ថ្លៃធ្វើដំណើរមកកាន់មន្ទីរពេទ្យនៅរាជធានី ដល់អ្នកដែលគេបណ្តេញចេញ ក៏ប៉ុន្តែជាជំនួសវិញ រដ្ឋាភិបាលបានពឹងផ្អែកលើអង្គការក្រៅរដ្ឋាភិបាល ដើម្បីធានាដល់ការទទួលបានថ្នាំព្យាបាលបន្ត។

បន្ថែមលើនេះ មិនមានការពិចារណាអំពីផលប៉ះពាល់លើសុខភាពស្តីពីស្ថានភាពរស់នៅដ៏អាក្រក់ នៅឯទួល សំបូរ និងការខ្វះខាតនៃឱកាសរកប្រាក់ចំណូលនៅទីនោះឡើយ។ ស្ថានភាពរស់នៅឯទួលសំបូរបង្ករឱ្យមានការប្រថុយនឹងគ្រោះថ្នាក់លើសុខភាព ជាពិសេសចំពោះអ្នកដែលមានប្រព័ន្ធសាំុាងកាយងាយទទួលមេរោគ។ គ្រោះថ្នាក់ចំពោះអ្នករស់នៅជាមួយមេរោគអេដស៍ អាចជាការគំរាមកំហែងដល់អាយុជីវិត។ អ្នក

តាំងទីលំនៅបានរាយការណ៍ថា កំដៅក្នុងជម្រកស័ង្កសីដែលមានខ្យល់ចេញចូលតិចតួច គឺមានសភាពខ្ពស់ហួសហេតុ ដែលជាធម្មតា នាំឱ្យពួកគេមិនអាចស៊ូទ្រាំងនៅក្នុងបន្ទប់របស់ពួកគេនៅពេលរសៀលបានឡើយ ហើយពួកគេព្រួយបារម្ភថា ថ្នាំប្រឆាំងមេរោគរបស់ពួកគេ នឹងខូចក្នុងកំដៅនោះ ។

យើងខ្ញុំសូមយកឱកាសនេះ ថ្លែងប្រឆាំងនឹងការផាត់ចេញ ឬការដាក់ឱ្យនៅឯកោនូវអ្នករស់នៅជាមួយមេរោគអេដស៍ ដែលគោលនយោបាយបែបនេះលើកស្ទួយឱ្យមានការមើលងាយមើលថោក និងការរើសអើងជាបន្ត ហើយអាចធ្វើឱ្យមានគ្រោះថ្នាក់ដ៏មហាធ្ងន់ធ្ងរដល់សិទ្ធិទទួលបានការបង្ការ ការថែទាំ ការព្យាបាល និងសេវាគាំទ្រចាំបាច់ផ្សេងៗ ។

បន្ថែមលើនេះ យើងខ្ញុំទទួលស្គាល់ថា អ្នករស់នៅជាមួយមេរោគអេដស៍ មានសេចក្តីត្រូវការច្រើនជាងនេះ មិនមែនត្រឹមថ្នាំដើម្បីរស់ប៉ុណ្ណោះទេ ។ ពួកគេត្រូវការការថែទាំបន្ត ដែលជួយដោះស្រាយដល់ផលវិបាកខាងផ្លូវចិត្ត ផ្លូវច្បាប់ សង្គម និងខាងសេដ្ឋកិច្ចនៃការរស់នៅជាមួយមេរោគអេដស៍ និងដែលធានាដល់ទីជម្រក អាហារូបត្ថម្ភ និងការរកចំណូលសមស្រប និងសិទ្ធិទទួលបានការអប់រំ និងសេវាចាំបាច់ដទៃទៀត ។

អាស្រ័យដោយហេតុដូចពោលខាងលើនេះ យើងខ្ញុំស្នើរសុំទៅរាជរដ្ឋាភិបាលកម្ពុជា :

បញ្ឈប់ការបញ្ជូនគ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ទៅកាន់តំបន់តាំងទីលំនៅថ្មីនៅ ទួលសំបូរ

- លើកកំពស់ស្ថានភាពនៅតំបន់ទួលសំបូរ ដើម្បីឱ្យពួកគេទទួលបានបទដ្ឋានអប្បបរមាសម្រាប់លំនៅ ដ្ឋាន អនាម័យ និងទឹកស្អាតគ្រប់គ្រាន់
- ធានាដល់សិទ្ធិទទួលបានពេញលេញនូវសេវាកម្មពីផ្នែកពេទ្យដោយសមភាព រួមទាំងការព្យាបាលដោយថ្នាំប្រឆាំងមេរោគអេដស៍ ការព្យាបាលជំងឺឱកាសនិយម និងការថែទាំសុខភាពបឋមនិងការ ថែទាំតាមផ្ទះ

- ធ្វើការជាមួយអង្គការពាក់ព័ន្ធ និងប្រឹក្សាជាមួយគ្រួសារដែលនៅឯទួលសំបូររួចហើយនោះ ដើម្បីដោះស្រាយកង្វល់បន្ទាន់និងរយៈពេលយូរស្តីពីលំនៅដ្ឋាន សុខភាព សុវត្ថិភាព ការងារ និងសមាហរណកម្មទៅក្នុងសង្គម ក្នុងលក្ខណៈមួយដែលការពារសិទ្ធិនិងការចិញ្ចឹមជីវិតរបស់ពួកគេ
- ប្រើប្រាស់នីតិវិធីជ្រើសរើសប្រកបដោយតម្លាភាពនិងយុត្តិធម៌ ក្នុងការកំណត់សិទ្ធិទទួលបានលំនៅដ្ឋាននៅនឹងកន្លែងបូរីកីឡា និងផ្តល់ឱ្យគ្រួសារដែលមានសិទ្ធិទទួលបាននូវផ្ទះសម្បែងជាបន្ទាន់ (រួមទាំង ១១ គ្រួសារដែលរងផលប៉ះពាល់ដោយមេរោគអេដស៍ ដែលបានទទួលយល់ព្រមដោយអាជ្ញាធររួចហើយ) ចំពោះអ្នកទាំងឡាយដែលមិនមានសិទ្ធិទទួល អាជ្ញាធរគួរតែផ្តល់លំនៅដ្ឋានឱ្យបានសមរម្យ ។

សូមអរគុណចំពោះការពិចារណារបស់ឯកឧត្តម ។

ដោយសេចក្តីគោរពរាប់អាន

[ឈ្មោះរបស់អង្គការ]

**<u>Organizations:</u>**

ACCES
*Marseilles, France*

ACT UP Philadelphia
*United States*

Action SIDA Comoros
*Union of Comoros*

AIDS Action Now!
*Toronto, Canada*

AIDS Action
*United States*

The AIDS Consortium
*South Africa*

AIDS Law project
*South Africa*

AIDS Project Los Angeles
*United States*

AIDS and Rights Alliance for Southern Africa
*Namibia*

All-Ukrainian Network of People Living with HIV/AIDS
*Ukraine*

Alliance for Holistic and Sustainable Development of Communities
*India*

American Jewish World Service
*United States*

Andrey Rylkov Foundation for Health and Social Justice
*Russia*

Asia Catalyst
*United States*

Asian Harm Reduction Network
*Thailand*

Asia Pacific Council of AIDS Service Organizations
*Malaysia*

Asia Pacific Network of People Living With HIV/AIDS
*Thailand*

Asia Pacific Network of Sex Workers
*Malaysia*

ASUD
*France*

Balance
*Mexico*

BAOBAB for Women's Human Rights
*Nigeria*

Blood Ties Four Directions Centre
*Yukon, Canada*

Bolivian Network of People with HIV/AIDS
*Bolivia*

Brazilian Drug Policy Center – Psicotropicus
*Brazil*

British Columbia Persons with AIDS Society
*Canada*

Canadian Association of Nurses in AIDS Care
*Canada*

Canadian Harm Reduction Network
*Canada*

Canadian HIV/AIDS Legal Network
*Canada*

Canadian Treatment Action Council
*Canada*

Center for Reproductive Rights
*United States*

Center for Health Policy and Innovation.
*United States*

Centre for Human Rights
Faculty of Law, University of Pretoria
*South Africa*

Children Education Society
*Tanzania*

中国北京爱之方舟感染者信息支持组织
[in English: China Beijing Ark of Love Infected Persons Information Support Organization]
*China*

The Secretariat of the Coalition of Asia Pacific Regional Networks on HIV and AIDS
*Thailand*

Comision Internacional de los Derechos Humanos para Gays y Lesbianas
[in English: International Commission of Human Rights for Gays and Lesbians]
*Argentina*

Consejo Latinoamericano y del Caribe de Organizaciones No Gubermentales con Servicio en VIH/SIDA
[in English: Latin American and Caribbean Council of AIDS Service Organizations]

Cultura Joven
[in English: Youth Culture]
*Mexico*

East Europe and Central Asia Union of PWH Organizations

Egyptian Initiative for Personal Rights
*Egypt*

Foundation for Integrative AIDS Research
*United States*

*Fundación Estudio e Investigación de la Mujer*
[in English: Foundation for Women's Studies]
*Spain*

Fundación Argentina Pro Ayuda al Niño con Sida
[in English: Argentinian Foundation for the Support of Children with AIDS]
*Argentina*

GESTOS - Soropositividade, Comunicação y Gênero
[in English: GESTOS - Soropositivity, Communications and Gender]
*Brazil*

Global Action for Children
*United States*

Global Business Coalition on HIV/AIDS, Tuberculosis, and Malaria
*United States*

Global Effort for Women against AIDS
*Uganda*

Global Forum on MSM and HIV
*United States*

Global Network of People Living with HIV

Global Welfare Association
*Cameroon*

Gram Bharati Samiti
[in English: Society for Rural Development]
*India*

Grassroots Movement for Health and Development
*Malawi*

Grupo Esperanza y Vida
[in English: Hope and Life Group]
*Uruguay*

Grupo de Mujeres de Argentina
[in English: Women's Forum of Argentina]
*Argentina*

Health Equity and Law Clinic
Faculty of Law, University of Toronto
*Canada*

Health GAP (Global Access Project)
*United States*

Hepatitis, AIDS, Research Trust
*United States*

HIV&AIDS Legal Services Alliance
*Los Angeles, CA, United States*

Hong Guang Alliance
*China*

Human Rights Watch
*United States*

Intercambios Asociación Civil
*Buenos Aires, Argentina*

International AIDS Women's Caucus
*Argentina*

International Center for Advancement of Addiction Treatment
*United States*

Interagency Coalition on AIDS and Development
*Canada*

International Community of Women Living with HIV/AIDS
*United Kingdom*

International Council of AIDS Service Organizations
*Canada*

International Drug Policy Consortium
*United Kingdom*

International Harm Reduction Association
*United Kingdom*

International HIV/AIDS Alliance
*United Kingdom*

International HIV/AIDS Alliance in Ukraine
*Ukraine*

International Nursing Harm Reduction Network

International Women's Health Coalition
*United States*

INTILLA Asociación Civil
*Argentina*

International Network of People Who Use Drugs

International Transport Workers' Federation
*United Kingdom*

International Treatment Preparedness Coalition
*Thailand (Secretariat)*

Jamaica AIDS Support for Life
*Jamaica*

Japanese Network of People Living with HIV
*Japan*

Lawyers Collective
*India*

Lembaga Bantuan Hukum Masyarakat
[in English: Community Legal Aid Institute]
*Indonesia*

La Liga Colombiana de Lucha contra el Sida
[in English: Colombian Alliance to Fight AIDS]
*Colombia*

LIGA Bonaerense de Diversidad Sexual
[in English: Bonaerense Alliance for Sexual Diversity]
*Argentina*

Malaysian AIDS Council
*Malaysia*

Movimiento Latinoamericano y del Caribe de Mujeres Positivas
[in English: Latin America and Caribbean Movement of Positive Women]
*Uruguay*

National Council of Churches in India
*India*

National MSM and HIV Policy Advocacy & Human Rights Task Force
*India*

Naz Foundation
*India*

Networking Aids Community of South Africa
*South Africa*

Oasis de San Juan de Dios
*Mexico*

People's Health Movement USA
*United States*

Physicians for Human Rights
*United States*

Positive Malaysian Treatment Access & Advocacy Group
*Malaysia*

Positive Women Incorporated
*New Zealand*

Prevenir es Cuidar
[in English: To Prevent is To Cure]
*Argentina*

Protection Enfant SIDA
[in English: Protection of Children with AIDS]
*Democratic Republic of Congo*

PROYECTO SOL
*Philadelphia, Pennsylvania, United States*

Raks Thai Foundation
*Thailand*

Recovering Nepal
*Nepal*

Release
*United Kingdom*

Sampada Grameen Mahila Sanstha
*India*

Senderos Asociación Mutual
*Colombia*

Sex Workers Concern Group
*Hong Kong*

Sidaction
*France*

Society for Women Against AIDS in Africa
*Senegal*

Southern Africa HIV and AIDS Information Dissemination Service
*South Africa*

Thai AIDS Treatment Action Group
*Thailand*

Treatment Action Campaign
*South Africa*

Union Alernative Georgia
*Tbilisi, Georgia*

United Belize Advocacy Movement
*Belize*

Urban Health Research Initiative
*Vancouver, British Columbia, Canada*

Vikas Adhyayan Kendra's
[in English: Center for Development Studies**]**
*Mumbai, India*

WITNESS
*United States*

Women and Law in Southern Africa
*Zambia*

World Aids Campaign
*South Africa*

Yayasan Kesehatan Bali
[in English: The Bali Health Foundation]
*Indonesia*

Youth RISE International
*Canada*

**Individuals**

Tomoko Ako
Associate Professor, Waseda University
*Japan*

Professor Brook K. Baker
Northeastern U. School of Law, Program on Human Rights and the Global Economy
*United States*

Chris Beyrer MD MPH
Director, Center for Public Health and Human Rights, Johns Hopkins Bloomberg School of Public Health
*United States*

Dr. Graciela Biagini
University of Buenos Aires
*Argentina*

Alan Brotherton

R. Douglas Bruce MD MA MSc
Assistant Professor, Yale Center for Clinical Investigation Scholar, Yale University School of Medicine
*United States*

Wendy Chapkis
Professor, Sociology and Women & Gender Studies, University of Southern Maine
*United States*

Slyvia Chirawu
National Coordinator, WLSA Zimbabwe
*Zimbabwe*

Joanne Csete
Associate professor, Clinical Population and Family Health, Columbia Mailman School of Public Health
*United States*

Chris Curry MD PhD

Nancy M. Doctor
Attorney at Law
*Berkeley, California, United States*

Yu Fangqiang
*China*

Dhan Raj Ghimire
National Coordinator, Children at Risk Network
*Nepal*

Dr. Rajesh Gopal MD
Joint Director, Gujarat State AIDS Control Society
*India*

Sofia Gruskin JD MIA
Director, Program on International Health and Human Rights, Harvard School of Public Health
*United States*

Mauro Guarinieri
Senior International Consultant, Global Network of People Living With HIV/AIDS

Christina T. Holder JD
Uriel and Caroline Bauer Human Rights Fellow, Cardozo School of Law
*United States*

T. Jayashree
Independent Film maker
*Bangalore, India*

Ralf Jürgens
Consultant HIV/AIDS, Health, Policy and Human Rights

Thomas Kerr PhD
Assistant Professor, Department of Medicine, University of British Columbia
*Canada*

Alana Klein
Faculty of Law, McGill University
*Canada*

A. Marston
*United Kingdom*

Laura McGrew
*United States*

Nicholas mbae Njeru
*Kenya*

Alice M. Miller JD

David B. Olson
Barrister and Solicitor
*Toronto, Ontario, Canada*

Dr. Nancy Ordover
Nicholas Bartlett
University of California, San Francisco
*United States*

Edith Pilkington
*United States*

Sophie Pinkham

Supattra Pisetpattanakul
Executive Officer, AIDS Society of Asia and the Pacific
*Thailand*

Oswaldo Rada
*Colombia*

Mindy Jane Roseman JD PhD
Lecturer on Law, Academic Director, Human Rights Program, Harvard Law School
*United States*

Mahesh Sharma
Executive Board Member, HIV/AIDS and STI Control Board
*Kathmandu, Nepal*

Daniel Tarantola MD
Professor of Health and Human Rights, School of Public Health and Community Medicine
*Australia*

Isaac Tita
Réseau Africain des Personnes Vivant avec le VIH/SIDA- Afrique Centrale
[In English: African Network of People Living with HIV/AIDS- Central Africa]
*Cameroon*

Carole S. Vance PhD MPH
Mailman School of Public Health, Columbia University
*United States*

Christine S. Waters
Staff Attorney, Legal Services of Central New York, Inc.
*United States*

Stan Wong
*Singapore*

Tian Xi
*China*

**cc:**

Lok Chumteav Bun Rany Hun Sen
President, Cambodian Red Cross

Dr. Mean Chhi Vun,
Director, NCHADS, Cambodia

H.E. Teng Kunthy
Secretary General, Cambodia National Aids Authority

H.E. Kep Chuktema
Phnom Penh Municipal Governor

Douglas Broderick
UN Resident Coordinator, Cambodia

Tony Lisle
Country Coordinator, UNAIDS Cambodia

Michael O'Leary
Country Representative, World Health Organization Cambodia

Christophe Peschoux
Country Representative, Cambodia Office of the High Commissioner for Human Rights
of the High Commissioner for Human Rights

**ចម្លងជូន :**

លោកជំទាវ **ប៊ុន រ៉ានីហ៊ុនសែន**
ប្រធានកាកបាទក្រហមកម្ពុជា

លោកវេជ្ជបណ្ឌិត **មាស ឈីខុន**
នាយកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍
សើស្បែកនិងកាមរោគ

ឯកឧត្តម **តែង គន្ធី**
អគ្គលេខាធិកា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍

ឯកឧត្តម **កែប ជុតិមា**
អភិបាលរាជធានីភ្នំពេញ

**ឌុកភ្លឹស ប្រូដឺរិក**
អ្នកសម្របសម្រួលប្រចាំប្រទេសកម្ពុជា
របស់អង្គការសហប្រជាជាតិ

**តូនី លីសល**
អ្នកសម្របសម្រួលប្រចាំប្រទេសកម្ពុជា
របស់អង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍

**មីសែល អូលារី**
តំណាងប្រចាំប្រទេសកម្ពុជារបស់អង្គការ
សុខភាពពិភាពលោក

**គ្រីស្តូស ផេសឈូ**
តំណាងប្រចាំប្រទេសកម្ពុជារបស់ការិយាល័យឧត្តមស្នង

ការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា